**Weekly Bulletin (Week3) June, 2010**

# ព្រឹត្តិបត្រ ព័ត៌មានប្រចាំសប្តាហ៍ កសិកម្ម និងអភិវឌ្ឍន៍ជនបទ

## សេចក្តីព្រាងគោលនយោបាយស្តីពីការជំរុញការនាំចេញអង្ករទៅទីផ្សារអន្តរជាតិ

*(វិទ្យុអូស្ត្រាលី ២១ មិថុនា ២០១០)*

គណៈកម្មាធិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបើកការប្រជុំដើម្បីបញ្ចប់សេចក្តីព្រាងគោលនយោបាយស្តីពីការនាំចេញអង្ករ និងដើម្បីបញ្ជូនទៅគណៈរដ្ឋមន្ត្រីអនុម័ត។ ការជំរុញធ្វើគោលនយោបាយនាំចេញអង្ករនេះ ត្រូវបានគេមើលឃើញថា ដោយប្រទេសកម្ពុជាមានសក្តានុពលខ្ពស់ផ្នែកកសិកម្ម ដើម្បីគាំទ្រសេដ្ឋកិច្ចជាតិ នៅក្នុងគ្រាដែលសេដ្ឋកិច្ចពិភពលោកកំពុងជួបវិបត្តិ។ គោលនយោបាយនេះបានកំណត់អំពីការអនុវត្តការប្រមូលទិញស្រូវ ការស្តុកទុក ការកែច្នៃស្រូវ និងការនាំចេញអង្កទៅទីផ្សារអន្តរជាតិ។ រដ្ឋាភិបាលក៏គ្រោងធ្វើគោលនយោបាយទៅលើការនាំចេញកសិផលផ្សេងៗទៀតដូចជា កៅស៊ូជាដើម។

## ប្រទេស ៤នៅទ្វីបអាស៊ីមកបោះទុនជាង ២០០លានដុល្លារខាងវិស័យកសិកម្ម

*(វិទ្យុអូស្ត្រាលី ២០ មិថុនា ២០១០)*

ក្រុមប្រឹក្សាអភិវឌ្ឍន៍នៃប្រទេសកម្ពុជាបានសម្រេចយល់ព្រមឱ្យមានការបណ្តាក់ទុនលើវិស័យកសិកម្មក្នុងទឹកប្រាក់ជាង ២៣០ លានដុល្លារ ពីប្រទេសចំនួន ៤នៅទ្វីបអាស៊ី។ គម្រោងអភិវឌ្ឍន៍ចំនួន ៦ ដែលបានការអនុញ្ញាតិគឺមានផ្នែកផលិត និងចម្រាញ់កៅស៊ូ ដូងប្រេង និងស្ករ ដែលនឹងមានទីតាំងរោងចក្រនៅក្នុងខេត្តកំពង់ស្ពឺ ក្រចេះ និងខេត្តមណ្ឌលគិរី។ នៅក្នុងគម្រោងទាំងនេះ ការបណ្តាក់ទុនច្រើនជាងគេគឺចេញពីប្រទេសចិន ដែលមានទឹកប្រាក់ ១៤២លានដុល្លារ សម្រាប់គម្រោងផលិតស្ករត្នោត ២កន្លែងនៅខេត្តកំពង់ស្ពឺ។ ចំណែកខាងប្រទេសវៀតណាមវិញ មានគម្រោង ២សម្រាប់កាដាំដំណាំកៅស៊ូ និងចម្រាញ់កៅស៊ូនៅក្នុងខេត្តក្រចេះ ដែលមានទឹកប្រាក់ ៣៦លានដុល្លារ។

## អ្នកឯកទេសអាមេរិកៈ អង្ករសម្រិតបង្កើនអត្រាកើតជំងឺទឹកនោមផ្អែម

*(រស្មីកម្ពុជា ១៦ មិថុនា ២០១០)*

ក្រុមអ្នកឯកទេសអាមេរិកនិយាយថា ការទទួលទានអង្ករសម្រូប និងនំប៉័ងដែលធ្វើពីម្សៅគ្រាប់ធញ្ញជាតិសម្រូប ជំនួសឱ្យការទទួលទានអង្ករសម្រិតអាចកាត់បន្ថយអត្រាកើតជំងឺទឹកនោមផ្អែមបានមួយភាគបី។ ក្រុមស្រាវជ្រាវមកពី Harvard បាននិយាយថា អង្ករសម្រិតបង្កឱ្យកើតជំងឺទឹកនោមផ្អែម ពីព្រោះវាធ្វើឱ្យជាតិស្ករក្នុងឈាមកើនឡើង។ ពួកគេនិយាយថា អង្ករសម្រូប និងប្រភេទអាហារធ្វើពីគ្រាប់ធញ្ញជាតិសម្រូបដទៃទៀតគឺជាជម្រើសប្រកាបដោយសុខភាព ដោយសារវាកាត់បន្ថយជាតិគ្លុយកូសជាបន្តបន្ទាប់។

## គ្រោះចរាចរធ្វើឱ្យខាតបង់រាប់ពាន់ដុល្លារ

*(អេវីរីដេ ១៦ មិថុនា ២០១០)*

យោងតាមការសិក្សារបស់អង្គការជនពិការអន្តរជាតិបែលហ្សិកស្ដីពី ការខាតបង់ដោយសារគ្រោះថ្នាក់ចរាចរណ៍ក្នុងឆ្នាំ ២០០៩ បានរកឃើញថាជាមធ្យមប្រជាពលរដ្ឋកម្ពុជាចំណាយថវិកា លើការខូចខាតទ្រព្យ សម្បត្តិអស់១៥៧២ដុល្លារក្នុងមួយករណីគ្រោះថ្នាក់ចរាចរណ៍ដែលបណ្ដាលឱ្យមាន អ្នកស្លាប់និង៣៨៥៨ដុល្លារក្នុងមួយ ករណីគ្រោះថ្នាក់ចរាចរណ៍ ដែលបណ្ដាលឱ្យមានអ្នករងគ្រោះថ្នាក់ធ្ងន់ធ្ងរ។ ក្នុងឆ្នាំ ២០០៩ជាមធ្យមកម្ពុជាខាតបង់ថវិកាអស់២៤៨លានដុល្លារដោយគ្រោះថ្នាក់ចរាចរណ៍។

## សកម្មភាពក្មេងទំនើងមានការថយចុះ

*(អេវីរីដេ ១៦ មិថុនា ២០១០)*

បើតាមរបាយការណ៍របស់លោកឧត្តមសេនីយ៍ឯកម៉ក់ជីតូប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ ក្រសួងមហាផ្ទៃ ថ្លែងក្នុងឱកាសបើក "សិក្ខាសាលា បណ្ដុះបណ្ដាលអន្តរជាតិស្ដីពីការ អនុវត្តន៍ច្បាប់ប្រឆាំងនឹងក្មេងទំនើង"ដែលឧបត្ថម្ភដោយនគរបាលសហរដ្ឋអាមេរិក មកពីទីក្រុងឡូស អ៊ិនជឺឡេសនាព្រឹក ថ្ងៃទី១៤ខែមិថុនាឆ្នាំ ២០១០បានឱ្យដឹងថា សកម្មភាពក្មេងទំនើងដែលបច្ចុប្បន្នយើងកំពុងគ្រប់គ្រងមានចំនួន ៥៨៧២នាក់ក្នុងនោះស្រី៩នាក់ មាន ១២៥៨ក្រុម មានមេខ្លោង ១៣៤០នាក់ប្រៀបធៀបឆ្នាំ ២០០៩កន្លងមកក្មេងទំនើង ទូទាំងប្រទេស សរុបមានចំនួន ៨៥០០នាក់ស្រី ២៧នាក់មាន ១៥៩០ក្រុម។ ក្នុងកិច្ចប្រជុំនោះលោកប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌ក្រសួងមហាផ្ទៃក៏បានឱ្យដឹងដែរ ថាចំពោះសកម្មភាពកន្លងមករបស់ក្មេងទំនើងទាំងនោះពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ ចំនួន ៣១៥២នាក់ពាក់ ព័ន្ធការសេពប្រើប្រាស់ គ្រឿងញៀន ចំនួន ៧២៩ នាក់និងប៉ះ ពាល់សណ្ដាប់ ធ្នាប់សង្គមជាង៤០០នាក់។

## រំលោភផ្លូវភេទកុមារកើនឡើងឆ្នាំនេះ

*(អេវីរីដេ ១៦ មិថុនា ២០១០)*

អង្គការលីកាដូនិងអាដហុកបានបង្ហាញស្ថិតិនៃការរំលោភបំពានផ្លូវភេទលើកុមារក្នុងឆ្នាំ២០១០ដែលមានចំនួនកើនឡើង ពីមួយខែទៅ មួយខែធៀបទៅ នឹងអំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ យោងតាមអង្គការអាដហុកការរំលោភផ្លូវភេទលើអនីតិជនបានកើនឡើងជារៀងរាល់ខែលើកលែងតែខែមករាដែលបានថយចុះពី៣៧ករណីធៀបនឹង ២២ករណីក្នុងអំឡុងពេលដូចគ្នាកាលពីឆ្នាំ២០០៩។ ក្នុងឆ្នាំ ២០១០ករណីរំលោភលើអនីតិជនសរុបមាន១៣៥ករណីក្នុងនោះអង្គការលីកាដូបានទទួលទិន្នន័យនៃការ រំលោភលើ អនីតិជន៨៣ ករណីក្នុងឆ្នាំ២០១០ ធៀបនឹង ៨៧ ករណីក្នុង ឆ្នាំ២០០៩។

## រដ្ឋបាលជលផលជំរុញចលនាភូមិមួយផលិតផលមួយអំពីប្រហុកសៀមរាប

*(វិទ្យុអូស្រ្តាលី ១៦ មិថុនា ២០១០)*

រដ្ឋបាលជលផលជំរុញចលនាភូមិមួយផលិតផលមួយលើផលិតផលប្រហុកនៅសៀមរាប ដើម្បីធ្វើការកែលម្អគុណភាព សុវត្ថិភាព និងឧត្តមភាពលើផលិតផលខ្មែរក្នុងគោលបំណងជំរុញទៅកាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ពាក់ព័ន្ធនឹងបញ្ហានេះ លោកស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាបបញ្ជាក់ថា អ្វីដែលសំខាន់គឺការគិតគូរឱ្យបានហ្មត់ចត់ទៅលើការធ្វើឱ្យបានត្រឹមត្រូវ ទៅតាមស្តង់ដារបច្ចេកទេសអានាម័យ ជាពិសេសការកែច្នៃឱ្យមានគុនភាព សុវត្ថិភាព និងសុខភាពរបស់អ្នកប្រើប្រាស់។

## ក្រុមហ៊ុនវិនិយោគទុនធំៗនៅអាមេរិក កំពុងសម្លឹងមើលការដាក់ទុននៅកម្ពុជា

*(ដើមអំពិល ១៦ មិថុនា ២០១០)*

ក្រុមហ៊ុនវិនិយោគទុនធំៗ របស់សហរដ្ឋអាមេរិក កំពុងសម្លឹងមើលមក ទីផ្សារប្រទេសកម្ពុជា ដើម្បីស្វែង រកលទ្ធភាពក្នុងការវិនិយោគនៅទីផ្សារ ដែលកំពុងតែមាន សក្តានុពលប្រសើរ។ យោងតាមការបញ្ជាក់ ពីក្រុមប្រឹក្សាជំនួញរបស់អាមេរិក និងអាស៊ាន បានឱ្យដឹងថា ក្រុមប្រតិភូពាណិជ្ជកម្ម មួយបានធ្វើដំណើរមកកាន់ទៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ១៤ ដល់ ១៥ ខែមិថុនា ដើម្បីជាការជួយឱ្យបាន ប្រសើរឡើង នូវបរិយាកាសធ្វើវិនិយោគ ក្នុងប្រទេសកម្ពុជានិងជាឱកាសស្វែងយល់បន្ថែមពីទីផ្សារសម្រាប់ ក្រុមហ៊ុនថ្មីៗមួយចំនួន។ គួរបញ្ជាក់ថា តាមតួរលេខចុងក្រោយបានឱ្យដឹងថា ប្រទេសកម្ពុជានាំទំនិញចូលសហរដ្ឋអាមេរិក មាន ចំនួនជាងពីរពាន់លានដុល្លារក្នុងមួយឆ្នាំៗ ខណៈពេលដែលសហរដ្ឋអាមេរិកនាំទំនិញ ចូលកម្ពុជាមាន មិនដល់២០០លាន ដុល្លារផង។

## កម្ពុជានឹងមានមជ្ឈត្តករ ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មជាលើកដំបូង

*(ដើមអំពិល ១៦ មិថុនា ២០១០)*

កម្មវិធីបរិយាកាសវិនិយោគនៃ ក្រុមធនាគារពិភពលោក កំពុងតែរៀបចំវគ្គ បណ្តុះបណ្តាលសម្រាប់បេក្ខជន ៥៤នាក់ ដើម្បីក្លាយជាមជ្ឈត្តករផ្នែកពាណិជ្ជកម្ម ដំបូងនៅកម្ពុជា ដែលនឹងជួយដោះស្រាយ វិវាទក្នុងពាណិជ្ជកម្មនិងបង្កើនទំនុកចិត្តនៅ ក្នុងប្រព័ន្ធពាណិជ្ជកម្មកម្ពុជា។ កម្មវិធីនេះ ត្រូវបានបើកសម្ពោធនារសៀលថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១០ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ភ្នំពេញ ក្រោមអធិបតីភាពរបស់លោក ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីនិងជារដ្ឋ មន្ត្រីក្រសួង ពាណិជ្ជកម្ម។

លោក ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មមានប្រសាសន៍ថា "ការបណ្តុះបណ្តាលនិងការជ្រើសរើសមជ្ឈត្តករ ក្រុមដំបូងនេះ គឺជាជំហានដ៏សំខាន់ដើម្បី ឆ្ពោះទៅការកសាងស្ថាប័នមួយ ដែលឯករាជ្យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការដោះ ស្រាយវិវាទពាណិជ្ជកម្ម"។ លោកបានបន្ថែម ទៀតថា "យើងជឿជាក់ថា មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះនឹងជួយ បង្កើនទំនុកចិត្តលើប្រព័ន្ធពាណិជ្ជកម្មកម្ពុជា ដែលនេះជាកត្តាសំខាន់សម្រាប់ការលើក កម្ពស់ការវិនិយោគនិងកំណើនសេដ្ឋកិច្ចនិង ជាផ្នែកមួយនៃគោលនយោបាយចតុកោណ របស់រាជរដ្ឋាភិបាល"។

## ស.រ.អា.ឱ្យចំណាត់ថ្នាក់លេខ ២ដល់កម្ពុជាក្នុងរបាយការណ៏រត់ពន្ធមនុស្ស

*(វិទ្យុអាស៊ីសេរី ១៥ មិថុនា ២០១០)*

ការិយាល័យឃ្លាំមើល និងប្រឆាំងអំពើរត់ពន្ធមនុស្សនៃក្រសួងការបរទេសសហរដ្ឋអាមេរិក បានចេញរបាយការណ៏ប្រចាំឆ្នាំនៅថ្ងៃទី ១៤ មិថុនា ដោយធ្វើចំណាត់ថ្នាក់កម្ពុជាក្នុងបញ្ហារត់ពន្ធមនុស្សឱ្យនៅលំដាប់ថ្នាក់លេខ ២។ លំដាប់ថ្នាក់លេខ ១ គឺសំដៅដល់ប្រទេសដែលរដ្ឋាភិបាលអនុវត្តតាមបានទាំងស្រុងទៅនឹងបទដ្ឋានច្បាប់ការពារជនរងគ្រោះដោយការជួញដូរ។ គេរកឃើញថាមូលហេតុធ្វើឱ្យដំណើរការបំបាត់អំពើជួញដូរ ឬរត់ពន្ធមនុស្សមិនបានជោគជ័យទាំងស្រុងមកពីមានអំពើរពុករលួយ និងនិទ្ទណ្ឌភាព ឬភាពមិនផ្តន្ទាទោសជលល្មើសតាមច្បាប់។

## ការវិនិយោគផ្ទាល់របស់បារាំងនៅកម្ពុជាមានការកើនឡើង

*(វិទ្យុបារាំង ១៤ មិថុនា ២០១០)*

សេចក្តីប្រកាសព័តិមានរបស់ស្ថានទូតបារាំងប្រចាំនៅកម្ពុជាបានបញ្ជាក់ឱ្យដឹងថា ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារប្រទេសបារាំងមានការកើនឡើងប្រមាណជា ១២លានអឺរ៉ូក្នុងរយ:ពេលបីឆ្នាំចុងក្រោយនេះ ពោលគឺបានកើនឡើងពី ៧១លានអឺរ៉ូនៅឆ្នាំ ២០០៧ មកដល់ ៨៣លានអឺរ៉ូនៅក្នុងឆ្នាំ ២០០៩កន្លងមក។ ការវិនិយោគផ្ទាល់របស់បារាំងនៅកម្ពុជាមានការកើនឡើងពី ៧៥លានអឺរ៉ូ នៅឆ្នាំ ២០០៦ មកដល់ ៩១លានអឺរ៉ូនៅឆ្នាំ ២០០៨កន្លងមក។

## តម្លៃគ្រាប់ស្វាយចន្ទីឡើងខ្ពស់នៅចុងបញ្ចប់នៃការប្រមូលផល

*(ឌឺភ្នំពេញប៉ុស្តិ៍ ដេលី ១១ មិថុនា ២០១០)*

មន្ត្រីកសិកម្ម និងឈ្មួញលក់គ្រាប់ស្វាយចន្ទីបាននិយាយថា តម្លៃគ្រាប់ស្វាយចន្ទីបានឡើងខ្ពស់ដោយសារការប្រមូលផលបានតិចជាងមុន និងតម្រូវការខ្ពស់ជាងមុនពីប្រទេសវៀតណាម ពេលដែលរដូវប្រមូលផលស្វាយចន្ទីបានបញ្ចប់នៅក្នុងខែឧសភានេះ។ អ្នកស្រីសុភាពជាឈ្មួញលក់គ្រាប់ស្វាយចន្ទីនៅខេត្តកំពង់ចាមថ្លែងថា តម្លៃបានកើនឡើងពី ៣៥០០រៀលក្នុងខែកុម្ភៈទៅ ៤៣០០រៀលក្នុង មួយគីឡូក្រាមក្នុងខែឧសភា ហើយថាកាលពីឆ្នាំមុនអ្នកស្រីទិញតែត្រឹមតម្លៃ ២៨០០រៀលក្នុងមួយគីឡូក្រាម។ ដែលការឡើងថ្លៃនេះ ត្រូវអ្នកស្រីពន្យល់ថា គឺដោយសារ ការមានតម្រូវការខ្ពស់ និងការប្រមូលផលបានតិច ដោយសារការជំនួសចំការស្វាយចន្ទីដោយចំការកៅស៊ូវិញ។

លោកសៀង ប៉េងស្រ៊ាង ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាមបានថ្លែងថា ផលស្វាយចន្ទីនៅក្នុងខេត្តលោកបានធ្លាក់ចុះប្រមាណមួយភាគបួនធៀបនឹងឆ្នាំមុនគឺពី ៤០ពាន់តោន មកនៅត្រឹម ៣០ពាន់តោន។ លោកម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មថ្លែងថា ដោយសារការនាំចូលគ្រាប់ស្វាយចន្ទីចំនួន ៦០ពាន់តោនពីប្រទេសកម្ពុជាកាលពីឆ្នាំទៅ ប្រទេសវៀតណាមបានក្លាយជាទីផ្សារធំបំផុតទីពីរក្នុងពិភពលោកសម្រាប់គ្រាប់ស្វាយចន្ទីបន្ទាប់ពីប្រទេសឥណ្ឌា។